# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែក ការស្តារលទ្ធភាពពលកម្មកាយសម្បទា

ICRC

## សង្ខេបគម្រោង

បច្ចុប្បន្ននេះ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) កំពុងបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ.) ក្នុងការគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាធំជាងគេទាំងពីរនៅខេត្តបាត់ដំបង និងកំពង់ស្ពឺ ដោយផ្តល់សេវាប្រចាំឆ្នាំ៥០ភាគរយទូទាំងប្រទេស។ មជ្ឈមណ្ឌលស្តារទាំងពីរនេះ មិនត្រឹមតែរក្សា និងពង្រឹងស្តង់ដាវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបម្រើជាមជ្ឈមណ្ឌលអប់រំ និងការអភិវឌ្ឍវិស័យស្តារលទ្ធភាពពលកម្មក្នុងតំបន់ និងសាកលលោក។ កម្មវិធីនេះបានជះឥទ្ធិពលក្នុងការផ្លាស់ប្តូរដល់អ្នកទទួលផល និងក្រុមគ្រួសាររបស់ពួកគេ ក៏ដូចជាប្រទេសជាតិទាំងមូល។ នៅពេលដែលក្នុងតំបន់មានថាមវន្តនេះបន្តវិវឌ្ឍ យើងនៅតែប្តេជ្ញាធានាថា សមាជិកដែលជាជនងាយរងគ្រោះបំផុតនៃសង្គមមិនត្រូវបានគេទុកចោល។ មជ្ឈមណ្ឌលស្តារទាំងនេះបានផ្តល់លើសពីសេវាជាសារវន្ត ដោយចូលរួមផ្តល់សិទ្ធិអំណាចដល់អ្នកចូលរួមកម្មវិធីតាមរយៈ ការផ្តល់ឱ្យនូវឧបករណ៍ជំនួយជាច្រើនដូចជា អវយវៈសិប្បនិម្មិត រណប រទេះរុញ និងគ្រឿងជំនួយដើរផ្សេងៗ ទន្ទឹមនោះក៏បង្កើតឱកាសការងារផងដែរ។

## លទ្ធផលរំពឹងទុករបស់គម្រោង

ICRC ឯកភាព និងគាំទ្រសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ក្នុងការផ្ទេរវិស័យស្តារលទ្ធភាពពលកម្មកាយសម្បទា ពីក្រសួង ស.អ.យ. ទៅក្រសួងសុខាភិបាលស្របតាមអនុសាសន៍អង្គការសុខភាពពិភពលោក និងឆ្លុះបញ្ចាំងពីនិន្នាការសកលផងដែរ។ យើងខ្ញុំសូមវាយតម្លៃខ្ពស់នូវសារសំខាន់នៃកិច្ចសហការអន្តរវិស័យ ដើម្បីសម្របសម្រួលបង្កើតឱ្យមាននូវយន្តការបញ្ជូនប្រកបដោយបរិយាបន្នសង្គមមួយដែលមានប្រសិទ្ធិភាពរវាងក្រសួងទាំងពីរនេះ។ បន្ថែមពីកិច្ចខិតខំប្រឹងប្រែងនេះ សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ទទួលបានការគាំទ្រមួយដ៏សំខាន់ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍន៍នូវកម្មវិធីនិស្សិតផ្នែកព្យាបាលដោយចលនា អាហា-រូបករណ៍សម្រាប់និស្សិត និងវគ្គបណ្តុះបណ្តាលបុគ្គលិកដ៏ទូលំទូលាយ។ ជាពិសេស និស្សិតជំនាន់ទីមួយផ្នែកព្យាបាលដោយចលនាបានចាប់ផ្តើមកាលពីឆ្នាំ ២០២១ តំណាងឱ្យព្រឹត្តិការណ៍មួយ ក្នុងការជំរុញវិជ្ជាជីវៈឯកទេសសុខាភិបាល។ អង្គការ ICRC ក៏ជាសមាជិកមួយនៃក្រុមប្រឹក្សាភិបាលរបស់មហាវិទ្យាល័យវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណបកម្ពុជា ដែលបានទទួលស្គាល់ជាអន្តរជាតិផងដែរ។ ICRC ក៏ផ្តល់អាហាររូបករណ៍ដល់និស្សិតជាច្រើនមកពីប្រទេសកម្ពុជា ស៊ូដង់ខាងត្បូង សូម៉ាលី និងមីយ៉ាន់ម៉ា។ ផលជះរបស់យើង លើសពីការផ្តល់ការអប់រំ និងការស្តារលទ្ធភាពពលកម្ម ខណៈដែលយើងចាប់យកវិធីសាស្ត្ររួមមួយ ក្នុងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់សេវា។ គំនិតផ្តួចផ្តើមទាំងនេះ រួមបញ្ចូលនូវការចុះឈ្មោះក្នុងកម្មវិធីសេដ្ឋកិច្ចខ្នាតតូច ការបណ្តុះ

បណ្តាលវិជ្ជាជីវៈ ឱកាសការងារ និងការធ្វើឱ្យប្រសើរឡើងក្នុងការទទួលបានការអប់រំ និងកីឡា។ ឧទាហរណ៍ វឌ្ឍនភាពដ៏គួរកត់សម្គាល់ ដែលបានធ្វើឡើងដោយសហព័ន្ធកីឡាបាល់បោះរទេះជនពិការកម្ពុជា (ដែលបង្កើតឡើងដោយអង្គការ ICRC) បានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា ពង្រឹងដល់សារសំខាន់នៃកីឡាប្រកបដោយបរិយាបន្ន។

## សកម្មភាពសំខាន់ៗ

- គាំទ្រការផ្តល់សេវានៅតាមមូលដ្ឋានក្នុងមណ្ឌលស្តារខេត្តកំពង់ស្ពឺ និងខេត្តបាត់ដំបង និងខេត្តប្រាំទៀតដែលមានព្រំប្រទល់ជាប់នឹងខេត្តទាំងពីរដូចជា ខេត្តកោះកុង ប៉ៃលិន ពោធិសាត់ បន្ទាយមានជ័យ និង ឧត្តរមានជ័យ
- វិធីសាស្រ្តផ្តល់ភាពអង់អាចដល់អ្នកទទួលសេវា លើសពីផ្តល់ការអប់រំ និងស្តារលទ្ធភាពពលកម្ម យើងក៏បញ្ចូលសកម្មភាពបរិយាបន្នដូចជាការបញ្ជូនទៅទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញផ្សេងៗ និងគាំទ្រនិស្សិតឱ្យចូលសិក្សានៅសាកលវិទ្យាល័យ។ តាមរយៈគំនិតផ្តួចផ្តើមសេដ្ឋកិច្ចខ្នាតតូច ដែលបានផ្តល់ភាពអង់អាចគាំទ្រដល់ស្ត្រី និងបុរសដើម្បីបំពេញតម្រូវការ ការងារ និងជីវភាពរស់នៅ។
- ពង្រឹងប្រព័ន្ធសកម្មភាពផ្សេងៗដើម្បីធានាបាននៅអន្តរកាលប្រកបដោយជោគជ័យនៃវិស័យស្តារលទ្ធភាពពលកម្ម ពីក្រសួង ស.អ.យ. ទៅក្រសួងសុខាភិបាល រួមទាំងការបង្កើតប្រព័ន្ធបញ្ជូនសម្រាប់អ្នកទទួលសេវា រវាងក្រសួងទាំងពីរ ដើម្បីធានាបរិយាបន្នសម្រាប់ជនមានពិការភាព។

## អ្នកទទួលផល

ជនមានពិការភាពនៅកម្ពុជា

## តំបន់គោលដៅ

- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាភូមិភាគខេត្តបាត់ដំបង គ្របដណ្តប់លើ ខេត្តបាត់ដំបង ពោធិសាត់ ប៉ៃលិន បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ គ្របដណ្តប់លើខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

## ដៃគូអនុវត្តគម្រោង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/មូលនិធិជនពិការ ក្រសួងសុខាភិបាល លើសពីនេះយើងសហការជាមួយភាគីពាក់ពន្ធ័ទាំងអស់ដែលរួមបញ្ចូលExceed Worldwide។

## រយៈពេលអនុវត្តគម្រោង

ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៦

## ព័ត៌មានទំនាក់ទំនង

| | |
|---|---|
| ICRC<br>ឈ្មោះ៖ Marc Zlot ប្រធានកម្មវិធីស្តារលទ្ធភាពពលកម្មកាយសម្បទា<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩៨៥ ៦៣៧<br>អ៊ីម៉ែល៖ mzlot@icrc.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ Vivath.Chou@access2cambodia.org |



គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។


ខែមីនា ឆ្នាំ២០២៤